# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ ផលប្រយោជន៍នៃធម្មយាត្រា
## ទៅប្រទេសឥណ្ឌា ។

website ៖ www.hoksavann.org

ថ្ងៃទី១២ ឧសភា ២០០៩



អ្នកប្រាជ្ញស្រាវជ្រាវប្រវត្តិព្រះពុទ្ធសាសនាចង់ដឹងការពិតថា ព្រះពុទ្ធត្រាស់ដឹងពិតប្រាកដឬទេ ? ភស្តុតាងជាច្រើន ដែលគេយកមកសំអាងថា ព្រះពុទ្ធពិតជាត្រាស់ដឹងពិតប្រាកដមែន គឺកន្លែងប្រសូតត្រាស់ដឹងសំដែងធម្មចក្របរិនិព្វាន ដើមពោធិព្រឹក្ស ព្រះសារីរិកធាតុនៃព្រះអង្គនៅប្រទេសនេប៉ាល់ និងប្រទេសឥណ្ឌាសព្វថ្ងៃនេះ ។ សំអាងដ៏រឹងមាំមួយទៀត គឺមគ្គប្រកបដោយអង្គ ៨ ដែលរួមមកបានដល់សីលសមាធិនិងបញ្ញា ដែលជាផ្លូវប្រតិបត្តិឆ្ពោះទៅរកការត្រាស់ដឹងជាព្រះពុទ្ធ ។

គ្រប់ជនជាតិដែលគោរពព្រះពុទ្ធសាសនា ដែលនៅក្នុងចំណោមនោះមានពុទ្ធសាសនិកជនខ្មែរ បានធ្វើដំណើរធម្មយាត្រាទៅកាន់ប្រទេសឥណ្ឌា ដើម្បីទៅថ្វាយបង្គំបូជនីយដ្ឋាននានានៃព្រះពុទ្ធ ដូចជាកន្លែងព្រះអង្គត្រាស់ដឹងនៅពោធិគយាជាដើម និងដើម្បីឲ្យឃើញភស្តុតាងថា ព្រះពុទ្ធពិតជាបានត្រាស់ដឹងពិតប្រាកដមែន ។ នៅប្រទេសកម្ពុជា ពុទ្ធសាសនិកជនខ្មែរកាន់ព្រះពុទ្ធសាសនា ៩៥% មានពុទ្ធសាសនិកជនខ្មែរខ្លះ ដែលមានលទ្ធភាពបានទៅប្រទេសឥណ្ឌា ដើម្បីពិនិត្យមើលបូជនីយដ្ឋានរបស់ព្រះពុទ្ធទាំងនោះឲ្យដឹងការពិត ។ ការសិក្សាស្រាវជ្រាវឲ្យដឹងការពិតនេះ ជាសកម្មភាពមានប្រយោជន៍សំរាប់ឲ្យខ្លួនជឿការ

គ្រាស់ដឹងរបស់ព្រះពុទ្ធបានច្បាស់លាស់ផង ហើយផ្សាយឲ្យពុទ្ធសាសនិកជនខ្មែរដែលមិនបានទៅបានដឹងផង ។

ប៉ុន្តែគួរស្តាយចំពោះមេដឹកនាំក្រុមធម្មយាត្រាខ្លះ ពេលទៅដល់បាននិយាយជ្រុលហួសហេតុពេក អំពីផលប្រយោជន៍នៃការឃើញបូជនីយដ្ឋានទាំងនោះរហូតដល់អ្នកធម្មយាត្រាខ្លះមិនត្រឹមតែបរិច្ចាគបច្ច័យទេ គេបរិច្ចាគទាំងមាសពេជ្រថែមទៀត ។ ជាឧទាហរណ៍ តាមវីដេអូ កាលពីប៉ុន្មានឆ្នាំមុននេះ គេឃើញធម្មយាត្រាខ្មែរមួយក្រុមទៅប្រទេសឥណ្ឌា នាំគ្នាវែបច្ច័យមានខ្លះសទ្ធាជ្រុលដោះមាសដោះពេជ្របូជាទីកន្លែងដែលតំកល់ព្រះសារីរិកធាតុ ដែលកាន់កាប់ដោយព្រះសង្ឃជាតិឥណ្ឌាមួយអង្គ ។ តាមការពិនិត្យមើល ព្រះសង្ឃជាតិឥណ្ឌានោះមានអាកប្បកិរិយាមិនសមខ្វះការសង្រួម ដូចជាយកព្រះហស្តច្រានស្រីជាដើម ។ បញ្ហាព្រះសារីរិកធាតុនោះពិតឬមិនពិតជារឿងមួយ ព្រោះឃើញតែកោដិពីខាងក្រៅ ។ ការបរិច្ចាគបច្ច័យរហូតជិតមួយម៉ឺនដុល្លារ និងមាសពេជ្រជាច្រើនទៀត តើព្រះសង្ឃជាតិឥណ្ឌាយកទៅណា ព្រោះមិនកសាងអ្វីទេ ។ ការធ្វើអ្វីមួយក៏ត្រូវមានបញ្ញាពិចារណា ហើយអ្នកដឹកនាំគណៈធម្មយាត្រាកុំនិយាយណែនាំរហូតដល់នាំឲ្យគេមានសទ្ធាជ្រុលរហូតដល់ដោះមាសដោះពេជ្រ ឲ្យព្រះសង្ឃជនជាតិឥណ្ឌានិងស្រីលង្កា ដោយយករូបបដិមាព្រះពុទ្ធ ឬយកព្រះសារីរិកធាតុក្លែងក្លាយជាមធ្យោបាយ ។ ខ្មែរទាំងនោះមានជំនឿជ្រុល ដោយសារអ្នកដឹកនាំគណៈធម្មយាត្រាចេះតែនិយាយអំពីអានិសង្សនៃការបូជា ប៉ុន្តែការបូជានេះពុំមែនបូជាព្រះពុទ្ធទេ ព្រោះរបស់ដែលបូជានោះត្រូវជនជាតិទាំងនោះយកទៅចាយវាយចិញ្ចឹមជីវិតយ៉ាងសប្បាយរីករាយ ។ អ្នកខ្លះគ្មានគិតពីបាបបុណ្យអ្វីទេ យកសាសនាព្រះពុទ្ធជាមធ្យោបាយដើម្បីលាភសក្ការៈ ។

អំពីបញ្ហាទាឋធាតុ (ព្រះចង្កូម) របស់ព្រះពុទ្ធ ថាព្រះចង្កូម១ចិនកុម្មុយនិស្តបានអះអាងថានៅប្រទេសរបស់គេ តើពិតគួរជឿឬទេ ? ។

នៅក្នុងគម្ពីរព្រះត្រៃបិដកភាគ១៦ ទំព័រ៣៤៩ និងទំព័រ៣៥០ ព្រះចង្កូមរបស់ព្រះពុទ្ធទាំង៤នោះ ពុំឃើញមាននៅប្រទេសចិនទេ ។ ក្នុងព្រះត្រៃបិដកភាគ១៦ នោះនិយាយថា «ព្រះទាឋា (ចង្កូម)១ ពួកទេវតានាំយកទៅបូជា ព្រះទាឋា១ទៀត ពួកជនធ្វើសក្ការបូជាក្នុងគន្ធារបុរី ព្រះទាថា១ទៀត ពួកជនធ្វើសក្កាបូជា

ក្នុងដែនរបស់ស្តេចកាលិង្គ ព្រះទាឋា១ទៀត ពួកនាគរាជនាំយកទៅធ្វើសក្ការបូជា» ។ យោងតាមអត្ថបទនេះ គន្ធាបុរីនិងដែនរបស់ស្តេចកាលិង្គ ទំនងជានៅប្រទេសឥណ្ឌា ។ តើចិនកុម្មុយនិស្តបានព្រះចង្កូមរបស់ព្រះពុទ្ធនេះពីណាមក ? ឬជារបស់សិប្បនិមិត្ត ? ។ ឯប្រទេសស្រីលង្កាក៏អះអាងថា ព្រះចង្កូមរបស់ព្រះពុទ្ធមួយនៅប្រទេសរបស់គេដែរ ។ ចំពោះប្រទេសចិនកុម្មុយនិស្ត កាលអំឡុងឆ្នាំ១៩៦០ បានធ្វើបដិវត្តន៍វប្បធម៌រំលាយគ្រប់ជំនឿសាសនាទាំងអស់មានព្រះពុទ្ធសាសនាជាដើម ឥឡូវនេះបែរជាលើកតំកើងព្រះពុទ្ធសាសនា រហូតថាមានព្រះចង្កូមព្រះពុទ្ធនៅក្នុងប្រទេសរបស់ខ្លួន តើគួរជឿឬទេ ? ។

ឥឡូវនេះ មានគណៈធម្មយាត្រាខ្មែរមួយក្រុម ធ្វើដំណើរពីភ្នំពេញទៅប្រទេសចិនកុម្មុយនិស្ត ដើម្បីទៅនមស្សការព្រះចង្កូមរបស់ព្រះពុទ្ធនេះ ។ មេដឹកនាំធម្មយាត្រានេះថែមទាំងបានទទួលយកមាសពេជ្រប្រាក់ពីអ្នកបរិច្ចាគ ទៅឲ្យចិនកុម្មុយនិស្តក្រោមរូបភាពបូជាព្រះចង្កូម បានទាំងរាប់ឈ្មោះតាមវិទ្យុ ហើយនិ-យាយប្រាប់ពីអានិសង្សឲ្យខ្មែររាប់លាននាក់ស្តាប់ផង ។

នេះជាការឃោសនាធ្វើឲ្យខ្មែរលង់គំនិត ជាអំពើមិនត្រូវធ្វើសោះឡើយ ។

*(<u>**យោបល់អន្តរបូរី**</u> ៖ យើងបានសង្កេតឃើញមានពុទ្ធសាសនិក និងព្រះសង្ឃខ្មែរជាច្រើននាក់និងច្រើនអង្គ នៅតាមវត្តនានានៅសហរដ្ឋអាមេរិក បានប្រមូលគ្នាជាពួកជាក្រុម ពពាក់ពូន ធ្វើដំណើរទៅកាន់ប្រទេសឥណ្ឌានិងស្រីលង្កាជារៀងរាល់ឆ្នាំ ។ មានខ្លះឬអង្គខ្លះបានធ្វើដំណើរទៅជាច្រើនដងថែមទៀតផង ។ សួរថា តើដំណើរទាំងអស់នេះនឹងនាំមកនូវចំណេះដឹងខាងព្រះពុទ្ធសាសនា ឬចំរើនមគ្គផលអ្វីដល់ជីវិតរស់នៅដែរឬទេ ? ។ យើងបានសង្កេតឃើញថា ពុំមានអ្វីប្លែកក្រៅអំពីពេលត្រឡប់មកវិញ និយាយអួតប្រាប់តៗគ្នា អំពីការបានទៅដល់និងទៅឃើញដល់ទីកន្លែង ដែលព្រះពុទ្ធបានប្រសូតនោះប៉ុណ្ណោះ ។ រួចមានខ្លះនោះ រហូតមានអបិយជំនឿ បេះស្លឹកពោធិយកមកទុកជាទីសក្ការៈបូជាថែមទៀតផង ។*

*បើតាមការស៊ើបអង្កេតរបស់យើង ដំណើរធម្មយាត្រាដែលគេបានធ្វើឡើងកន្លងមកនេះ ត្រូវចំណាយប្រាក់កាសយ៉ាងច្រើនសន្ធឹកសន្ធាប់*

ណាស់ ដែលមួយភាគបានទៅក្រុមហ៊ុនទេសចរណ៍ ហើយនិងមួយភាគធំបានជាប្រាក់ចំណូលសំរាប់ប្រទេសឥណ្ឌានិងស្រីលង្កា ក្នុងវិស័យទេសចរណ៍របស់ជាតិគេ ។ ការនិយាយអំពីថាមានព្រះទាឋានៅប្រទេសនេះ ឬនៅប្រទេសនោះ គឺជាល្បិចឃោសនាដើម្បីទាក់ទាញទេសចរណ៍ឲ្យធ្វើដំណើរទៅកាន់ប្រទេសរបស់គេ ។ ទាក់ទាញទេសចរបានចំនួនច្រើនកាលណា ប្រាក់ចំណូលរបស់ក្រុមហ៊ុននិងរបស់ជាតិគេក៏កើនឡើងយ៉ាងច្រើនដែរ ។ បើតាមយើងដឹង ពុទ្ធសាសនិកខ្មែរយើងបានចំណាយជាច្រើនម៉ឺនដុល្លារក្នុងមួយឆ្នាំៗសំរាប់ធម្មយាត្រានេះ ។

យោបល់របស់យើង, យកល្អគួរទុកប្រាក់ទាំងអស់នោះសំរាប់កសាងវត្តអារាមនៅតាមសហគមន៍រៀងៗខ្លួន ឬមួយក៏យកទៅកសាងព្រះវិហារ ឬកុដិសាលានៅតាមភូមិកំណើតឯប្រទេសកម្ពុជាវិញទៅ ។ យ៉ាងហោចណាស់ លោកអ្នកបានធ្វើប្រយោជន៍ដល់សាសនានិងប្រទេសជាតិរបស់លោកអ្នក ហើយនិងជាពិសេសបំផុតនោះបានបន្សល់ទុកនូវស្នាដៃដ៏ល្អប្រសើរសំរាប់កូនចៅរបស់យើងតទៅអនាគតផង) ។

❄ ❄

❄